BMI0134

# សម្ភាសន៍ជាមួយឈ្មោះ ជួន វ៉ន ភេទស្រី អាយុ៥៨ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ កងចល័តនារីនៅអាងត្រពាំងថ្ម

## សព្វថ្ងៃរស់នៅភូមិប៉ោយក្តឿង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ហ៊ិន សុធានី

០០:៤៦:២១

២៣ទំព័រ

ធានី : ថ្ងៃនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ។ ខ្ញុំឈ្មោះ ធានី មកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះមកនេះចង់សាក់សួរពីប្រវត្តិរឿងរ៉ាវរបស់មីង ដែលមីងបានឆ្លងកាត់កាលពីសម័យខ្មែរក្រហម ។ ហើយរឿងរ៉ាវទាំងអស់នេះ ពួកខ្ញុំសុំយកមកចងក្រងធ្វើជាសៀវភៅ ហើយក៏ដូចជាសម្រាប់អ្នកសិក្សាស្រាវជ្រាវផ្សេងៗ ទុកឲ្យក្មេងៗជំនាន់ក្រោយបានរៀនបានសូត្រ ។ ចឹងសុំថតជាសម្លេង ក៏ដូចជារូបថតអីមីងបានទេ?

វ៉ន : ដឹងថតម៉េច ខ្ញុំមិនសូវប៉ុននិយាយក្បោះក្បាយទេ អារឿងនិយាយ ។

ធានី : តែមីងអនុញ្ញាតិដែរ មែនទេមីង?

វ៉ន : មិនបានទេ ។

ធានី : បានហើយអត់?

វ៉ន : ថតធ្វើអី មាននិយាយប្រាប់នាងឯងតិចៗទៅ ។ ថាកាលនោះវាពិបាកណាស់ គេឲ្យទៅរែកដីត្រពាំងថ្មៗមុនដូងរែកម៉ាតិចទេ ១ម៉ែត្រ ២ម៉ែត្រ តាមកម្លាំងសិន ដល់ពេលយូរទៅគេដាក់ឲ្យ៥ម៉ែត្រគីប ប៉ុននឹងឯងមានទៅនិយាយច្រើន ។ ត្រង់ណារែកមិនរួចទៅ ក៏គេវ៉ៃហើយ ។

ធានី : ចឹងមីងអត់ទោស មីងឈ្មោះអីដែរ?

វ៉ន : ខ្ញុំនឹងឈ្មោះ ជួន វ៉ន ។

ធានី : ឆ្នាំនឹងអាយុប៉ុន្មាន?

វ៉ន : ខ្ញុំ៥០ជាង ៥៧ ៥៨ ។

ធានី ៖ ៥៧ ៥៨?

វ៉ន ៖ ៥៨ ។

ធានី ៖ មីងមានស្រុកកំណើតនៅណាដែរ?

វ៉ន ៖ ស្រុកនេះ ភូមិនេះ ។

ធានី ៖ ស្រុកកំនើតនៅភូមិឃុំអីដែរ?

វ៉ន ៖ ភូមិប៉ោយក្តឿង ឃុំព្រះនេត្រព្រះ ។

ធានី ៖ ភូមិប៉ោយក្តឿង ឃុំព្រះនេត្រព្រះ ស្រុកអី?

វ៉ន ៖ ស្រុកព្រះនេត្រព្រះ ។ ភូមិប៉ោយក្តឿង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ។

ធានី ៖ ខេត្តបន្ទាយមានជ័យ?

វ៉ន ៖ ហ្នឹងហើយ ។ នាងអើយ វែក កាលនឹកឃើញវាឆ្អែតៗខ្លួនឯងនិយាយមិនចេញ ។

ធានី ៖ ឪពុកមីងឈ្មោះអីដែរ?

វ៉ន ៖ ឈ្មោះ ដួន ទិត ។

ធានី ៖ ដួន ទិត?

វ៉ន ៖ ចាំ!

ធានី ៖ គាត់ខូចពេលណាដែរ?

វ៉ន ៖ ខូចជំនាន់គ្រួសារខ្ញុំគាត់ចាំ ប៉ុនខ្ញុំវាភ្លេច ខូចសម័យនេះឯង មិនខូចសម័យនោះទេ ទៅវែកក៏វាលំបាកៗម៉េចទេ ។ មុនដំបូងគេឲ្យវែក ២ម៉ែត្រៗរួចគេថែម ៣ម៉ែត្រៗរួចគេថែម៤ម៉ែត្រៗរួចគេថែម៥ម៉ែត្រ ។ ដល់៥ម៉ែត្រវែកមិនរួចទេ វែកដល់វាស់ល្ងាចៗហើយ បើយើងតូនត្អែរថាមិនរួចគេវ៉ៃចោល ។ ហើយចេះតែសួរ បើអ្នកណារួចមុនក៏ជួយគ្នាវែកទៅរួចមកទាំងអស់គ្នា ។ ដល់ពេលមកឡើងដើរគោងដៃគ្នាបណ្តើរម៉ោង១០ នេះទំនប់ត្រពាំងថ្ម ។ ហើយការហូបចុក ក៏គេវាស់បាយទុកឲ្យហូប ម៉ាចានចង្កឹះទៅ ។

ធានី ៖ ចឹងកាលនឹង មីងនៅអាងត្រពាំងថ្មនឹង ពេលណា?

វ៉ន ៖ មិនដែលចាំទេ មិនដែលគិតចាំថា ខែណា ថ្ងៃណា បញ្ជូនទៅ ដឹងតែគេបញ្ជូនទៅវែក មិនដឹង ខែណា ថ្ងៃណាទេ ក្នុងពេលនោះមិនដែលគិតជំនុំគ្នា២នាក់ ឬ៣នាក់ទេ មិនដែលហ៊ានសួរ ថាយើងថ្ងៃណាមក ខែណាមក ខ្លាចតែមិនរួចគេវ៉ៃចោល មិនដឹងថាបានទៅវិញ ឬមិនបាន ព្រោះអ្នកទៅវែកហើយសុទ្ធប្រេជ្ញាថាមានតែការផាប់ច្រើនជាង ។(និយាយចង់យំ)

ធានី ៖ ចឹងការទៅរែកនឹង រែកខែប្រាំង ខែវស្សា?

វ៉ន ៖ ខែប្រាំង មើលជិតយើងច្រូតក្រោមរួចគេដេញកម្ទាំងឲ្យមកផ្ទះ ប៉ុនមិនដឹងថ្ងៃណា ខែណាទេ ។

ធានី ៖ ប៉ុន្តែឲ្យតែខែប្រាំងបានយើងទៅរែក ឬក៏យើងរែកតែខែប្រាំងមួងទេ?

វ៉ន ៖ រែកហើយនៅនោះតែម្តង ។

ធានី ៖ ខែវស្សាក៏នៅ?

វ៉ន ៖ ខែវស្សារែកទំនប់ធំនោះរួច ហើយចុះមកតាមប្រឡាយនឹងនៅដើមគរ៣ដើម ។

ធានី ៖ ចឹងយើងខែប្រាំងយើងទៅធ្វើនៅត្រពាំងថ្មនឹង?

វ៉ន ៖ ទេ! ទៅលើកម្តង ។

ធានី ៖ ដល់ពេលខែវស្សាបានយើងមកធ្វើខាងប្រឡាយ?

វ៉ន ៖ ធ្វើម្តងនឹងរួចហើយៗ ក៏បញ្ជូនកម្ទាំងចុះមកបណ្តើរៗ ។

ធានី ៖ ធ្វើម្តងនឹងធ្វើពេលណា ដូចថាពេលម៉ាប្រាំងនឹងឬម៉េច?

វ៉ន ៖ ធ្វើម៉ាប្រាំង កម្ទាំងជញ្ជូនទាំងអស់គ្នា តែម៉ាប្រាំងនឹងយើងវ៉ៃសំរុកឲ្យរួចហើយ ឃុំយើងកម្ទាំងប៉ុន្មានរយ ទៅស្រុកយើងកម្ទាំងប៉ុន្មានរយទៅសរុបគ្នាទៅ ក៏លើកទៅណាបានម៉ាប្រាំងនឹងឯង ។ ដល់ពេលចុះទៅវិញទៅ គេលើកកម្ទាំងទី១ទប់នៅដើមគ កម្ទាំងទី២គេបញ្ជូនមកភូមិ ។ ពេលមកភូមិមិនមែនបញ្ជូនមកផ្ទះតែម្តង មកភូមិតែម្តងទេ លើកទំនប់បណ្តើរ ទំនប់តូច ប្រឡាយតូចបណ្តើរៗ ។ ហើយពួកខ្ញុំលើកទំនប់នឹងរួច ខ្ញុំនៅឈប់ដកកម្ទាំងទឹកនោះឯង នៅធ្វើស្រែ ។

ធានី ៖ ចឹងមីងនៅកម្ទាំងទី១ ឬទី២?

វ៉ន ៖ កម្ទាំងទី១ ។

ធានី ៖ កម្ទាំងទី១នឹងនៅកន្លែងណា មីងថានៅ?

វ៉ន ៖ ដើមគ៣ដើម ។

ធានី ៖ នៅស្អីគេ?

វ៉ន ៖ ពីដើមមិញគេហៅគ៣ដើម ខាងជើងព្រៃមាន់ ។

ធានី ៖ គ៣ដើម ។ ដើមគនឹងមែន?

វ៉ន ៖ ដើមគ៣ដើម ។

ធានី ៖ ហៅគ៣ដើមទេ តាមពិតដើមគ វាមាន៣ដើម ។ គេហៅគ៣ដើម?

វ៉ន ៖ ហ្នឹងឯង គពាដើមនឹងមិនដឹងនៅណាទេ គេហៅគពាដើម នៅធ្វើស្រែ លុះគ្រាតែចប់មកហើយ ។ នឹងគេអត់ឲ្យមកផ្ទះវិញទេ ។

ធានី ៖ ចុះកម្លាំងទី២នឹង គេនៅណាវិញ?

វ៉ន ៖ កម្លាំងទី២ គេបញ្ជូនមកតាមភូមិ ។ ប៉ុនមុនមកតាមភូមិ គេឲ្យលើកទំនប់ប្រឡាយជីកអាមុខត្រពាំងថ្ម មកចុះៗ ។

ធានី ៖ ដេញមកតាមភូមិ?

វ៉ន ៖ ហ្នឹងហើយ គេថាជីកទម្លាក់មកទៅដូនជ្រែង ជីកតាមទៅនឹងទៅ បើពួកខ្ញុំនៅធ្វើស្រែនោះ ។ ដល់គេជីកអស់រួចហើយ បានគេចូលភូមិទៅ ។

ធានី ៖ ចឹងកាលមុនដំបូង កាលមីងបានធ្វើការនៅត្រពាំងថ្មនឹង មីងនៅណាវិញ?

វ៉ន ៖ នៅភូមិយើង នៅស្រែគេច្រូតស្រូវ ។

ធានី ៖ ចង់និយាយថា ពេលនឹងប្រជាជនថ្មី គេចូលមកដល់ មកនៅ?

វ៉ន ៖ មកនៅហើយ ទៅទាំងអស់គ្នានឹង ។

ធានី ៖ មកនៅពេលណា?

វ៉ន ៖ អើយ!នាងអើយ! មិនបានគិតថាចាំមកពេលណាពេលណែ ចេះតែគិតតែខ្លាចហើយកូន ។ ហើយណាមួយស្រណោះគ្នាអ្នកថ្មី មិនដែលគិតថាគេថ្មីឯងចាស់ មិនដែលគិតចុះទេ ។ ប៉ុនតែគេនៅតែនិយាយ បើគេអ្នកធ្វើការ គេថាបែងចែកឲ្យយើង អ្នកចាស់ៗ ។ តែបើយើងទៅធ្វើការជាមួយគ្នា ដូចបងប្អូន ។ ចំពោះខ្ញុំ បើគេមិនដឹងទេ បើខ្ញុំគិតថាដូចបងដូចប្អូនជួយគ្នាហៅគ្នា ។

ធានី ៖ ចុះម៉េចបានគេបែងចែកថ្មីចាស់ចឹង?

វ៉ន ៖ មិនដឹងគេគិតម៉េច អង្គការគេនឹង មិនមែនយើងអ្នកនៅនឹង បែងចែកឲ្យគេទេ ។ រឿងពិតនិយាយឡើងវាកំសត់ណាស់ ។ មើលទៅទំនប់នឹងវាធំធេង មើលទៅមិនរួចប្រហែលជាមិន បានទៅផ្ទះទេ ។ គិតតែប៉ុននឹង គិតថាមិនបានទៅផ្ទះ មិនរួចទេច្បាស់ជាស្លាប់នេះឯង ។ មិនដឹងថាវាយ៉ាងម៉េច គិតៗប៉ុននឹង ហើយស្គមអស់ហើយនារីគ្មានទឹកដីក ។

ធានី ៖ អត់មានទឹកដីក?

វ៉ន ៖ អឺ! ....គ្មានទឹកដីក ។

ធានី ៖ ម៉េចចឹងមីង?

វ៉ន ៖ ទឹកមកដងនៅត្រពាំងថ្មនេះ ។

ធានី ៖ ហ៉ា! មកដងនៅត្រពាំងថ្មម៉េច ធ្វើការនៅត្រពាំងថ្ម ម៉េចទៅដងនៅត្រពាំងថ្ម?

វ៉ន ៖ អឺ! ស្តាប់ឲ្យបាន កន្លែងត្រពាំងថ្មចេះ មុនដំបូងយើងលើកនៅកន្លែងត្រពាំង ដល់ពេលយើងលើកទៅទៀត ទៅកូនខ្វែងអត់មានទឹកដឹកទេ លើកបន្តម៉ាខ្សែត្រៀមៗ ម៉ាវគ្គវា មិនមែនលើកម៉ាត្រពាំងថ្មនឹង លើកនៅត្រពាំងថ្មនឹងទេ ។ លើកទី១ស្ពានរាប ។

ធានី ៖ លើកដំបូងស្ពានរាប?

វ៉ន ៖ ហ្នឹងហើយ លើកដំបូងស្ពានរាប ។ ដល់លើកពីស្ពានរាបទៅបានទៅលើកកូនខ្វែង អានឹងកន្លែង ។ ដល់ទៅកូនខ្វែងអត់ទេ ហូបទេ ។ ដល់អត់មានទឹកហូប ម្នាក់មកដងម្តងដងដឹក ។ ចង់ដឹកឆ្អែតមកវែកខ្លួនឯងម្នាក់ ប្រធានក្រុមគ្នាយើងចេះ ឲ្យទៅដងម្នាក់ម្តងទៅ បានដឹកឆ្អែត ។

ធានី ៖ ហើយបន្ទាប់មកទៀត ទៅលើកណាទៀត មានស្ពានរាប កូនខ្វែង ហើយមានណាទៀត?

វ៉ន ៖ អត់ទេត្រឡប់មកផ្ទះវិញហើយ ។

ធានី ៖ ពេលនឹងមីងត្រឡប់មកផ្ទះវិញហើយ?

វ៉ន ៖ មិនមែនមកផ្ទះទេ មកនៅដើមគនឹង ។

ធានី ៖ គ៣ដើមនឹង?

វ៉ន ៖ ហ្នឹង ។

ធានី ៖ នៅគ៣ដើមនឹង ទៅធ្វើអីទៀត?

វ៉ន ៖ នៅធ្វើស្រែ ។

ធានី ៖ នៅគ៣ដើមនឹង យើងលែងលើកទំនប់ យើងនៅធ្វើស្រែធ្វើអីវិញ?

វ៉ន ៖ នៅធ្វើស្រែៗប្រាំង ។

ធានី ៖ តែមីងឈប់លើកទំនប់ទៀតហើយ?

វ៉ន ៖ គេឈប់ឲ្យលើកហើយ ។

ធានី ៖ មីងលើកទំនប់តែម្តងទេ គេឲ្យលើក?

វ៉ន ៖ ប៉ុនខ្ញុំមិនលើកតែម្តងទេ ពេលមុនទៅកូនខ្វែងនេះ ខ្ញុំទៅសាលាក្រហម ។

ធានី ៖ ទំនប់សាលាក្រហមមួយទៀត?

វ៉ន ៖ ហ្នឹងហើយ ប៉ុនសាលាក្រហមនឹង មិនមែនទំនប់ធំប៉ុន្មានទេ តាមមើល ទំនប់ ។

ធានី ៖ នៅណាវិញសាលាក្រហមនឹង នៅភូមិ?

រ៉ន ៈ អឺ! ទៅជិតខាងប៉ោយប៉ែតហើយ ទៅសុភី សីង្ហានោះណា ទៅនោះម្តង ប្រូតស្រូវរួចគេឲ្យ លើកទំនប់ អត់មកផ្ទះទេ ។

ធានី ៈ ចឹងទៅខាងប៉ោយប៉ែតវិញ?

រ៉ន ៈ ហ្នឹងហើយ ។

ធានី ៈ ដល់កូនដីរីទេ?

រ៉ន ៈ មិនដឹងកូនដីរីម្តុំត្រង់ណា មិនដែលហ៊ានសួរគេទេ ។

ធានី ៈ ម្តុំទឹកថ្លា?

រ៉ន ៈ ទេ! ហួសទឹកថ្លា ។

ធានី ៈ មានទំនប់នឹងមួយ នៅសាលាក្រហម?

រ៉ន ៈ ហ្នឹងហើយ ទំនប់នោះ ។

ធានី ៈ តែប៉ុននឹងហើយ?

រ៉ន ៈ មកភូមិម្តង គេបញ្ជូនឲ្យទៅប្រូតហើយឡើងទៅទំនប់ ។

ធានី ៈ ឡើងទៅទំនប់?

រ៉ន ៈ ឡើងទៅទំនប់ត្រពាំងថ្មនឹង ។

ធានី ៈ ចឹងមុនដំបូងមីងថាមីងទៅត្រពាំងថ្មហើយ?

រ៉ន ៈ ទេ! មុនដំបូងខ្ញុំទៅទំនប់នេះមុន ។

ធានី ៈ ទៅសាលាក្រហមមុន?

រ៉ន ៈ ហ្នឹងហើយ ឡើងពីសាលាក្រហមបានខ្ញុំទៅត្រពាំងថ្ម ។

ធានី ៈ ចឹងសាលាក្រហមទី១?

រ៉ន ៈ ប៉ុនអ្នកភូមិនេះ អត់មានអ្នកណាទៅទេ ទៅតែខ្ញុំ២នាក់ទេ ។

ធានី ៈ អ្នកណាគេម្នាក់ទៀត?

រ៉ន ៈ ម្នាក់ទៀត...អាពួកនោះដូនទៅ ។

ធានី ៈ គាត់ឈ្មោះអីគេ?

រ៉ន ៈ ឈ្មោះ វណ្ណី ។

ធានី ៈ វណ្ណីនឹងទៅលើកទំនប់នៅសាលាក្រហមតែ២នាក់នឹង?

រ៉ន ៈ ហ្នឹង ។

ធានី ៈ ហើយជាមួយមនុស្សប៉ុន្មាននាក់?

វ៉ន :  គ្នាច្រើន តែភូមិគេ ។

ធានី :  ចាំទេ មនុស្សប៉ុន្មាននាក់?

វ៉ន :  ច្រើនរាប់រយ ។

ធានី :  ជិះប៉ុន្មានឡាន?

វ៉ន :  មិនមែនជិះទេ ថ្មើរជើង មុនដំបូងនៅប្រួតនៅសាលាក្រៅ កន្លែងរោងម៉ាស៊ីន ប្រួតរួចហើយ គេឲ្យដើរទៅ ។

ធានី :  ដឹងថាអ្នកណាគេអ្នកឲ្យទៅ?

វ៉ន :  ដឹងអ្នកណា ដឹងថាអង្គការឲ្យទៅសាលាក្រហម ។ ដឹងអង្គការអ្នកណា ។

ធានី :  អ្នកណាគេប្រាប់មីងថា អង្គការ?

វ៉ន :  ភូមិ ក្រុមៗ តែប្រធានក្រុមមិនមែនអ្នកស្រុកយើងទេ វាបែកគ្នា ពេលនោះចេះតែមកពីណាពីណែជុំគ្នា ។ ដល់ពេលចប់បែករកស្រុករកភូមិ រៀងខ្លួន ។

ធានី :  អត់ដឹង?

វ៉ន :  អត់ដឹង ពេលណាកំពុងតែប្រួតៗចឹង គេថាអង្គការស្មើម៉ាក្រុម មិនដឹងអ្នកណាអង្គការទេ ម៉ាក្រុមចេះ មាន៨-១០-២០នាក់ ក៏គេបញ្ជូនឲ្យទៅ មិនដឹងអ្នកណា មិនស្គាល់គេទេ យើងខ្លាចស្លាប់ចេះទៅៗ ។

ធានី :  ចឹងមីងទៅសាលាក្រហមហើយ ទំនប់សាលាក្រហមនឹង អ្នកណាគេអ្នកគ្រប់គ្រងនៅទំនប់នឹង?

វ៉ន :  អ្នកគ្រប់គ្រងទំនប់នឹង ឈ្មោះតាស្រួចៗ ប៉ុនខ្ញុំអត់ដែលឃើញគេថាទំនប់កូនចៅតាស្រួច គេថាចឹង ។

ធានី :  តាស្រួចនឹង អ្នកគ្រប់គ្រង?

វ៉ន :  អ្នកគ្រប់គ្រង ប៉ុនមិនដឹងអ្នកណាគាត់ទេ ។

ធានី :  អត់ដែលស្គាល់គាត់?

វ៉ន :  ទេ! ដែលខ្ញុំក្ដ មិនហ៊ានមើលមុខគេ ។

ធានី :  មីងក្ដឈ្មោះគាត់នឹងមកពីអ្នកណាគេប្រាប់?

វ៉ន :  គ្នាយើងណា ចង់ទៅផ្ទះ សុំតាស្រួចទៅ ។ តែមិនដឹងមួយណាទេ មិនហ៊ានមើលមុខគេទេ ។

ធានី :  ដែលធ្លាប់មានអ្នកណាគេសុំទៅផ្ទះ?

វ៉ន ៈ ទេ! គ្មានណាហ៊ានទៅសុំ ឈឺទៅដេកពេទ្យទៅ ប្រធានកងមិនដឹងអ្នកស្រុកណាទេ .......មក សរសេរទៅ កត់ឈ្មោះទៅ មើលទៅឲ្យទៅៗ ប៉ុននឹង មិនមានធ្វើទេ ។

ធានី ៈ ប្រធានកងឈ្មោះអីគេ?

វ៉ន ៈ មិនស្គាល់ទេ មិនស្រុកយើងទេ ។

ធានី ៈ មិនមែនស្រុកយើង អត់ស្គាល់ឈ្មោះទៀត?

វ៉ន ៈ ទេ! អត់ទេ ។

ធានី ៈ ដឹងគាត់មកពីស្រុកណា?

វ៉ន ៈ ទៅណា មិនដែលទៅសួរគេ អត់ហ៊ានតែដឹងទេ មិត្តនេះសួរធ្វើអីគេវៃចោល ។ ម្ល៉ះហើយ ទៅត្រង់ណាចេះតែធ្វើការទៅ កុំឲ្យតែងាប់ ។

ធានី ៈ មីងនៅធ្វើទំនប់សាលាក្រហមនឹងប៉ុន្មានថ្ងៃ ប៉ុន្មានខែ បានមក?

វ៉ន ៈ ទំនប់សាលាក្រហមទៅតែខែប្រាំង ប្រូតរួច ។

ធានី ៈ ចាំមើលពេលប្រជាជនថ្មីមកដល់ អត់ទាន់ទៅទេ ព្រោះខែវស្សា អន់ទាន់ទៅទំនប់សាលាក្រហមទេ យើងនៅធ្វើការនៅភូមិ?

វ៉ន ៈ ទេ! ប្រជាជនថ្មីមិនទាន់មកទេ ។

ធានី ៈ អាពេលទំនប់សាលាក្រហម?

វ៉ន ៈ ហ្នឹងហើយមិនទាន់មកដល់ទេ មកដល់ពេលទៅត្រពាំងថ្ម ។

ធានី ៈ មកដល់ពេលទៅត្រពាំងថ្ម?

វ៉ន ៈ ហ្នឹង ។

ធានី ៈ ចឹងពេលប្រជាជនថ្មីមកដល់?

វ៉ន ៈ មកដល់ ពេលយើងកម្លាំងនៅកើត ប្រជាជនថ្មីមិនដឹងមកស្ថានណាទេ ព្រោះយើងចេញទៅនៅក្រៅបាត់ៗ ។

ធានី ៈ ចឹងយកមីងទៅមុនហើយ?

វ៉ន ៈ នោះហើយ យើងនារីទៅនៅមុន នារីយុវជនទៅនៅមុខគេ គេហៅឈានមុខ ។

ធានី ៈ គេហៅឈានមុខ?

វ៉ន ៈ ហ្នឹងហើយ តែមិនដឹងអ្នកថ្មីមកពីស្ថានណា មិនដឹងទេ ។

ធានី ៈ ហើយមីងអត់ចាំអ្នកណាគេ អ្នកចាត់តាំងឲ្យមីងទៅ?

រ៉ន :	ស្លាប់អស់ហើយ ឈ្មោះ តាធាន ស្លាប់ហើយ ។ គ្មានទេ អ្នកចាត់តាំងចាស់ៗស្លាប់ហើយ ។ ស្លាប់អស់ហើយនៅតែតិចៗ ។

ធានី :	តាធាននឹង ត្រូវជាអីនឹងមីង?

រ៉ន :	ប្រធានភូមិ តែគេស្លាប់ហើយ ។ គេសួរអ្នកណាគេអ្នកឲ្យទៅ ថាតាធាននោះឯង គេចាត់តាំងឲ្យទៅ ឲ្យតែនារីយុវជន គេឲ្យទៅមុខ មកសួរលំអិតក្នុងភូមិមិនដឹងទេ ។

ធានី :	ចឹងពេលដែលមីងទៅទំនប់នៅសាលាក្រហមបានប្រជាជនថ្មីនៅភូមិយើងហើយ?

រ៉ន :	មិនដឹងគេមកពីស្ថានណាមិនដឹង បើខ្ញុំទៅសាលាក្រហម ។

ធានី :	ពេលណាបានមីងត្រឡប់ពីសាលាក្រហមមកវិញ?

រ៉ន :	ទាល់ចប់ឈើ មកដេកពេទ្យស្វាយ ។

ធានី :	ដេកពេទ្យស្វាយប៉ុន្មាន ពេលនឹងយើងធ្វើស្រែប្រាំង ស្រែវស្សាប៉ុន្មានដងហើយ?

រ៉ន :	អត់បានធ្វើអីទេ ដេកពេទ្យ អត់បានធ្វើស្រែប្រាំងអីទេ លើកទំនប់នៅសាលាក្រហម ពួកខ្ញុំ ។

ធានី :	ចង់និយាយថា មីងលើកទំនប់នៅសាលាក្រហម មីងលើកនៅខែវស្សា?

រ៉ន :	អឺ! ចុះប្រូតរួច គេឲ្យលើកហើយ ។

ធានី :	ខែប្រាំងនឹង ចង់និយាយថា ចុះពេលនឹងប្រជាជនថ្មីមកដល់ហើយ ។

រ៉ន :	មិនដឹងទេ ថានៅកន្លែងមុខព្រួញគេចុះ មិនដឹងថាមកដល់ហើយ ។

ធានី :	កាលមីងនៅសាលាក្រហមនោះ?

រ៉ន :	មិនទាន់មានឃើញទៅទេ មិនទាន់បញ្ជូនទៅទេ ។

ធានី :	ចង់និយាយថា ពេលមីងទៅសាលាក្រហមនឹង នៅខែប្រាំង ខែវស្សា?

រ៉ន :	ទៅខែប្រាំង ប្រូតហើយគេដឹងតែដកកម្លាំងទៅពីប្រូតទៅលើកទំនប់នេះ ។ គេដកកម្លាំងទៅលើកទំនប់ ។ វាពាឆ្នាំ យើងមិនលើកទំនប់សាលាក្រហមម៉ាឆ្នាំ ដល់ហើយយើងនៅត្រពាំងថ្មៗហើយនៅដើមគចប់បណ្ដោយ ។

ធានី :	ចឹងមីងអត់ដែលជួបប្រជាជនថ្មីសោះ?

រ៉ន :	ជួបនៅក្នុងភូមិ ។

ធានី :	នៅក្នុងភូមិពេលណា?

រ៉ន ៖ តែគេបញ្ជូនទៅ ដូចថាបញ្ជូនទៅនារីយុវជនទៅ មានប្រជាជនថ្មីគេមកហើយ ដូចអ្នកភ្នំពេញដែលថាជម្លៀសមក យើងប្រជាជនចាស់ គេជម្លៀសចេញដែរ ពីស្រុកយើងនេះគេមិនឲ្យយើងនៅត្រង់នេះទេ គេឲ្យទៅនៅត្រង់នោះ មិននៅក្នុងភូមិយើងទេណា ។

ធានី ៖ ចឹងបានន័យថា ពេលដែលមីងចេញទៅ គឺប្រជាជនថ្មីមកនៅ?

រ៉ន ៖ មកនៅហើយ ។

ធានី ៖ ចឹងតាំងពីខែវស្សា រហូតដល់ខែប្រាំង?

រ៉ន ៖ ខែវស្សា ពីខែយើងប្រូតរួចនឹងហើយប្រជាជនយើងមកនោះ ។ មិនដឹងទេ ខ្ញុំដឹងតែចេញមិនដឹងអ្នកណាមកស្មើណាស្មើណែទេ ដូចថាប្រធានគេមកមុន ប្រធានគេមកចាត់តាំងមុន ។

ធានី ៖ ប្រហែលជាប្រូតហើយ យើងគិតទៅអាចខែ៨ ខែ៩ ឬក៏ខែ១០ទេ?

រ៉ន ៖ ម៉េចខែ១០ ប្រូតហើយខែ១ ខែ២ហើយ មិនមានប្រូតខែ៨ ខែ៩ ខែ១០ ។

ធានី ៖ ព្រោះប្រជាជនថ្មីទម្រាំចូលមកដល់នេះ អាចខែ៩?

រ៉ន ៖ ប្រូត ខែប្រូត ខែ១ ។

ធានី ៖ មីងចាំបានពេលមីងនៅសាលាក្រហមនឹង?

រ៉ន ៖ មិនដឹងណាថ្ងៃខែទេ ព្រោះយើងទៅនៅមុខរបូត យុវជននារី ។

ធានី ៖ ចង់(ដឹង) ខែប្រាំងខែវស្សា ពេលនឹងមីងធ្វើស្រែប្រាំងរួច?

រ៉ន ៖ ដឹងប្រូតរួចៗ គេឲ្យធ្វើស្រែប្រាំង អឺ!លើកទំនប់ៗរួច គេឲ្យនៅប្រូតស្រែប្រាំង ។ ហើយសួរខ្ញុំ ដូចខ្ញុំមិនដែលនៅភូមិគេ ។ គេប្រូតខែប្រាំង ខែវស្សា ខែនេះខែនោះអត់ដឹងទេ ព្រោះប្រូតហើយ លើកទំនប់ៗរួចហើយ ខែទឹកចេះធ្វើស្រែប្រាំង ដឹងណាប្រាំងវស្សាដកស្ទូងៗ ។ ១

ធានី ៖ ចឹងខែប្រាំងក៏ដោយ ខែវស្សាក៏ដោយ ក៏ធ្វើស្រែ?

រ៉ន ៖ ដឹងតែធ្វើស្រែប្រាំង ខែវស្សា... ។

ធានី ៖ ចឹងកាលនឹងមីងទៅប្រូតខែប្រាំង ឬខែវស្សា ដែលប្រូតហើយ?

រ៉ន ៖ ប្រូតខែវស្សា ។

ធានី ៖ ចឹងបន្ទាប់មកទៀតមីងទៅ?

រ៉ន ៖ ត្រពាំងថ្ម ។

ធានី ៖ ពេលណាដែរ ពេលខែប្រាំង?

រ៉ន ៖ ប្រូតហើយ ទៅលើញអាងត្រពាំងថ្ម ។

ធានី ៖ កាលនឹងអ្នកណាគេ អ្នកចាត់តាំងឲ្យមីងទៅ?

វ៉ន ៖ អឺ! មិនដឹងណាទេ អ្នកស្រុកផ្សេងៗគ្នា បែកៗគ្នា អត់មានអ្នកនៅជាមួយគ្នាទេ មិនដឹងទេ ។

ធានី ៖ ចឹងមីងទៅសាលាក្រហម មីងចេញពីសាលាក្រហមហើយមកស្រុកយើងសិន?

វ៉ន ៖ មកស្រុកសិន ។

ធានី ៖ មកស្រុកសិនប្រហែលជាប៉ុន្មានខែ?

វ៉ន ៖ ហើយគេដាក់មុខព្រួញ មិនយូរទេ ចុះយើងទៅបើករបបនោះ យើងទៅបើកអង្ករប្រធានភូមិ ដល់ពេលមក យើងប្រាប់គេថាមានមនុស្សមកអង្ករមកពីនេះពីនោះ គេឲ្យរបបមកស៊ី បើយើងមិនប្រាប់គេដឹងថាអត់ ។ មកយ៉ាងណា២ថ្ងៃ គេតាមមកវិញហើយ កម្លាំងមកនារីសល់ប៉ុននេះ បញ្ជូនឲ្យទៅនោះទៀត គេមិនមែនឲ្យនៅទេ ។

ធានី ៖ ចឹងកាលមីងមកម៉េចបានមីងត្រឡប់មកភូមិ?

វ៉ន ៖ ឈឺជា ។

ធានី ៖ ឈឺអីគេ?

វ៉ន ៖ ឈឺញាក់ ។

ធានី ៖ ម៉េចបានមីងអត់ទៅសម្រាកនៅពេទ្យ?

វ៉ន ៖ ទេ! សម្រាកនៅពេទ្យហើយ សុំសំបុត្រពេទ្យមកគេនៅផ្ទះ ។

ធានី ៖ ព្យាបាលនៅពេទ្យហើយ បានសុំត្រឡប់មកផ្ទះ?

វ៉ន ៖ ហ្នឹងហើយតែសំបុត្រពេទ្យមកភូមិ ។

ធានី ៖ មីងនៅផ្ទះប៉ុន្មានថ្ងៃ បានត្រឡប់មកផ្ទះ?

វ៉ន ៖ នៅពេទ្យកន្លះខែ ។

ធានី ៖ កន្លះខែ បានត្រឡប់មកផ្ទះ បានប៉ុន្មានថ្ងៃ?

វ៉ន ៖ ៣ថ្ងៃទៅវិញ ។

ធានី ៖ ៣ថ្ងៃ មីងត្រឡប់ទៅណាវិញ?

វ៉ន ៖ ទៅកន្លែងដែរ ទៅប្រូតៗនោះ បៀតប្រាសាទ ដល់ពេលនោះគេប្រមូលកម្លាំងពីកន្លែងនោះ មកវិញ ។

ធានី ៖ ប្រូតបានប៉ុន្មានថ្ងៃប៉ុន្មានខែ?

វ៉ន ៖ ប្រូតបានម៉ាខែដែរច្រើនដែរ ។

ធានី ៖ ប្រូតបានម៉ាខែ បានមីងត្រឡប់ទៅត្រពាំងថ្មនឹង?

វ៉ន ៖ ហ្នឹងហើយ ។

ធានី ៖ កាលនឹងទៅលើកដំបូង ត្រពាំងថ្ម?

វ៉ន ៖ ហ្នឹងហើយ ។

ធានី ៖ ម៉េចបានគេទៅធ្វើការនៅត្រពាំងថ្ម?

វ៉ន ៖ យើងនារីយុវជន គេអ្នកយកទៅហើយ ។

ធានី ៖ ចង់និយាយថា ហេតុអីបានគេកសាងត្រពាំងថ្មនឹងធ្វើអី?

វ៉ន ៖ មិនដឹងគេទេ គេគ្រាន់ថាទៅលើកទំនប់ ។

ធានី ៖ អ្នកណាគេអ្នកប្រាប់?

វ៉ន ៖ គេហៅកម្លាំងទៅលើកទំនប់ គេថា ។ គេយកម៉ាសារមុនចឹងទៅ គេយក១០០នាក់ចឹងទៅ ១០០នាក់លើកមិនគ្រាន់ទេ ប្រមូលទៀត អ្នកនៅក្នុងភូមិចេះប្រមូលបណ្ដើរៗ ។

ធានី ៖ ចុះកាលមីងទៅប៉ុន្មាននាក់?

វ៉ន ៖ នាងអើយរាប់រយ ទាំងភូមិគេភូមិយើង ។

ធានី ៖ មីងមិនថាប្រមូលមិនមែនម្ដងទេ ច្រើនដងហើយ ។ ពេលដែលមីងទៅប៉ុន្មាននាក់?

វ៉ន ៖ ម៉ាឃុំយើង១០០ៗ ទៅមុនដំបូង ។

ធានី ៖ មីងទៅជាមួយគេ ឬក៏ទៅបន្ទាប់ៗ?

វ៉ន ៖ ទៅអាកាលមុន ឆ្នាំទី១ ទៅដើងមុនទី១ហើយ ១០០នាក់ម៉ាឃុំទៅ ដល់ពេលទៅបាន២-៣ថ្ងៃ គេប្រមូលទៅទៀត តែមិនដឹងប៉ុន្មានទេ ចេះប្រមូលៗទៅទាំងចាស់ទាំងក្មេង ។

ធានី ៖ ដល់ពេលមីងទៅមុនដំបូង ឃើញទំនប់នឹងយ៉ាងម៉េចទៅ?

វ៉ន ៖ មិនទាន់លើ ដីទទេរ ។

ធានី ៖ ដីទទេរ?

វ៉ន ៖ នៅទទេរ ។

ធានី ៖ ទំនប់នឹងកន្លែងអីគេ?

វ៉ន ៖ ដីទី ដីស្រែ តែមិនដឹងថាគេធ្វើថាយ៉ាងម៉េចត្រូវ ។ ចុះបើទៅរលីងចេះ ដីស្មើ ដីស្រែស្មើ ស្រាប់តែគេឲ្យយើងលើកៗឈើ លើព្រៃទៅ ដឹងថាយ៉ាងម៉េច សួរនាងថា ។

ធានី ៖ ចឹងដីស្មើធម្មតា គេចាក់ដីបន្ថែមលើ?

វ៉ន ៖ លើក អ្នកណាចាក់ៗខ្លួនយើង ។

ធានី ៖ យើងដឹកពីក្រោម?

វ៉ន ៖ ហ្នឹងហើយ ។

ធានី ៖ ចឹងមានប្រឡាយទឹកគេពីដើម?

អ្នកជិតខាង ៖ អត់មានទេ ឧបមាថា គេចាប់ផ្ដើមវាស់ពីត្រឹមណា ខាងដើងទំនប់ប៉ុនណា ២០ម៉ែត្រ ប្រឡាយទឹកត្រូវមានប៉ុន្មានម៉ែត្រ គេជីកពីនោះឯងឡើងដាក់មក គេវាស់ខ្សែគេតំរង់ទៅ ម៉ាក្រុមមានប៉ុន្មានម៉ែត្រៗ ម៉ាក្រុម១០នាក់ៗមានប៉ុន្មានម៉ែត្រ ក្នុងម៉ាម៉ែត្រគីបគេឲ្យលើក ម៉ាថ្ងៃឲ្យរួច ឬ២ម៉ែត្រគីប ។

វ៉ន ៖ អត់គិចទេវើយៗ ម៉ាថ្ងៃនោះ ៥ម៉ែត្រហើយ កម្ទាំងទី១នោះ ដាក់ឡើងហៀវ....អាកម្ទាំងទី២ ៣ម៉ែត្រ ។ អញមិនចាំអស់ទេ ព្រោះវាពិបាកចិត្តនឹងនិយាយ ខ្លាចថាខ្លាចស្លាប់ មិនដែលពិគ្រោះគ្នា ថាយើងរួចរឿងទៅណាមិនដែល ។ កន្លែងពិគ្រោះនោះវែកមិនរួចឥឡូវហើយ គេវ៉ៃចោលទៀត ។ ដល់ហើយទាល់តែវែក ។

ធានី ៖ ចុះមីងដឹងថាអ្នកណាគេដាក់ឲ្យមីងដាក់៥ម៉ែត្រគីប?

វ៉ន ៖ ប្រធានគេនោះ ។

ធានី ៖ ឈ្មោះអីគេ មីងចាំ?

វ៉ន ៖ មិនស្គាល់ទេ ស្រុកគេ ។

ធានី ៖ ប្រធានកង ឬក៏ប្រធានអី?

វ៉ន ៖ ប្រធានកង មិនស្គាល់គេទេ ស្រុកផ្សេងៗគ្នា ដល់ពេលនោះគេនៅជាមួយគ្នា រួមគ្នា ថ្ងៃនេះឡើង បើនិយាយផ្ដេសផ្ដាស់គេវ៉ៃចោល ។

ធានី ៖ ចឹងមីងដឹងថាធ្វើតាមគេប្រាប់ទៅ?

វ៉ន ៖ អឺ! ធ្វើតាមគេប្រាប់ ។

ធានី ៖ ហើយចឹងមីងអត់ដឹងថាទំនប់នឹង មានប្រវែងប៉ុន្មានអី?

វ៉ន ៖ អូ! មិនដឹងទេ មិនសួរគេទេ ខំតែវែកខ្លួនយើងឲ្យតែវែករបស់យើងទៅ ។

ធានី ៖ ហើយម៉ាថ្ងៃវែកដឹងបាន៥ម៉ែត្ររហូត?

វ៉ន ៖ ដឹងបាន៥ម៉ែត្ររហូត បើមិនរួចដឹងថាវ៉ៃចោលហើយ ប្រាប់មុនឲ្យហើយ គ្មានអ្នកណាធ្វើមិនបានទេ មានតែធ្វើបានៗ បើមិនធ្វើបានគឺដឹងថាស្លាប់ យប់ឡើងដឹងថាស្លាប់ហើយ ។

ធានី ៖ មីងឃើញ?

វ៉ន ៖ មីងមិនឃើញ មីងឃើញនឹងភ្នែកហើយ ម៉េចសួរមីងឃើញម៉េច ។

ធានី : ចង់និយាយថា ម៉េចបានមីងដឹងថា អ្នកដែលធ្វើអត់បានដឹងថាយប់ឡើងស្លាប់ មីងបានឃើញផ្ទាល់ភ្នែក?

រ៉ន : ចុះបើវាបាត់គ្នាហើយ នៅជាមួយគ្នា បើវាបាត់ម្នាក់វាទៅណា ដែលហ៊ានរត់ទៅផ្ទះទៅ ។

ធានី : ឈ្មោះអីគេដែលបាត់?

រ៉ន : មិនដឹងទេ ថាស្រុកផ្សេងគ្នា មិនដឹងទេ ។

ធានី : សូម្បីតែឈ្មោះក៏អត់ដឹងដែរ?

រ៉ន : អូ! អត់ដែលសួរគ្នាទេ ហើយបាត់អានោះទៅណា អត់ហ៊ានសួរទេ *“ចង់បាត់ផង?”* គេថាយើង គេសួរបេះ ។ វែកដាច់តែខ្សែបន្ទីរក៏ត្បូងចប គេប្រាប់មុនឲ្យហើយ នាងឯងចង់សួរអីទៀត ។ នាងឯងបាក់ដងវែក នាងឯងចង់មិនចង់ *“មិត្តឯងចង់?”* ។

ធានី : គេថាចឹង?

រ៉ន : គេថាចឹងឯងគេប្រាប់ឲ្យហើយ បន្ទីរមួយជនីកកាប់មួយ នាងឯងរក្សាដូចជាងមាសទៀត ។

ធានី : ហើយធ្លាប់មានដាច់មានអី?

រ៉ន : ទេ! ដាច់ដោយយើងវែកធម្មតា គេឲ្យ គេអត់ថាអីទេ តែយើងធ្វើជាដាច់ធ្វើជាអី នាងឯងបាត់ហើយ ។

ធានី : ចុះធ្វើបានដឹង មានយើងធ្វើដាច់ ឬយើង?

រ៉ន : ចុះអង្គការគេថា អង្គការភ្នែកម្នាស់ មិនបានទេ ហើយគេថានាងឯង ហើយនាងឯងសួរចឹង មិនដឹងនិយាយថាម៉េចត្រូវទេ គេថា *“ចង់មិនចង់ ចូល”* គេថាប៉ុននឹង គេថាយើងចូលរបត់ខ្នាំង ។ ឈើក៏ស្ទាបនាងឯង បើនាងឯងក្តៅមែនបាន បើនាងឯងអត់ក្តៅនោះហើយដងវែកនាងឯងមិនទៅ ។

ធានី : ឲ្យឃើញទាំងអស់គ្នា?

រ៉ន : ឲ្យឃើញទាំងអស់គ្នា ឲ្យខ្លាចទៅ បើយើងមិនឈប់... គេវៃប្រធានកងដែរ ។ ប្រធានកងគ្នា ខ្លាច វារត់មិនរួច ដែនការគេដាក់ចុះ ថ្ងៃនេះឲ្យរួចប៉ុននេះរយម៉ែត្រ គេបន្តបន្ទាប់គ្នា ។

ធានី : ចាំមើល មីងថាម៉ាថ្ងៃឲ្យបាន៥ម៉ែត្រចឹង ព្រោះប្រធានកង គ្នាមីង១០នាក់?

រ៉ន : អឺ!

ធានី : ចឹងប្រធានកងមួយទៀត ម៉ាថ្ងៃ៥ម៉ែត្រ ៥០ម៉ែត្រ?

រ៉ន : អឺ!

ធានី ៖ អត់រួច៥០ម៉ែត្រនឹង គឺវៃប្រធានកងចោលវិញ?

វ៉ន ៖ អឺ! ចឹងឯង បើនាងឯងសួរ នឹងប្រាប់ត្រង់ទេ។

ធានី ៖ ចឹងហូបចុកម៉េចដែរ?

វ៉ន ៖ ហូបចុក បាយម៉ាកូនចាន ឆ្អែតប៉ុននោះ មិនឆ្អែតប៉ុននោះទៅ។

ធានី ៖ បានបាយហូប?

វ៉ន ៖ បានបាយ។

ធានី ៖ តែម៉ាថ្ងៃ ឬម៉ាពេល?

វ៉ន ៖ ម៉ាពេល។

ធានី ៖ ចឹងបានបាយប៉ុន្មានពេល?

វ៉ន ៖ ២។

ធានី ៖ ២ពេលទេ បានព្រឹកហើយល្ងាច?

វ៉ន ៖ ហ្នឹងហើយ នេះកម្លាំងពិសេសគេហើយ បានគេឲ្យបាយនោះ បើអ្នកនៅភូមិគេមិនឲ្យទេ។

ធានី ៖ គេប្រាប់ចឹង?

វ៉ន ៖ គេត្រូវចឹងឯង។ ....តែគេដឹកអង្ករឲ្យដឹងខាងណាគេ។

ធានី ៖ ហើយមីងហូបបាយជាមួយអីគេដែរ?

វ៉ន ៖ ជួនណាទឹកអំបិល ជួនណាគេបានត្រីឆ្អៀត គេយកទន្លេសាបនោះមួង។

ធានី ៖ តែនឹងសម្រាប់តែមីង?

វ៉ន ៖ ទាំងអស់គ្នានឹង ទាំងរាប់ពាន់នាក់។

ធានី ៖ ចុះមីងគិតថាការហូបនឹង ហូបគ្រប់គ្រាន់ទេ?

វ៉ន ៖ វាមិនឆ្អែតទេ តែនៅក្រោមរបបគេហើយ ខ្ញុំត្រូវតែស៊ូ។

ធានី ៖ ដូចម្ហូបហូបចុកអីចឹង ដូចថាមើលទៅថាវាស្អាត បាត មានអនាម័យ?

វ៉ន ៖ អូ! គ្មានអីអនាម័យ បើគ្មានទាំងរយ ទាំងពាន់។

ធានី ៖ ចឹងធ្វើម៉េច?

វ៉ន ៖ ដាក់ម៉ាស្លាបព្រា ២ស្លាបព្រាទៅ គេជួសដាក់កញ្ជើរទៅ ដឹកទៅ គេចែកឲ្យ ចុងភៅគេបើក ឲ្យយើងហូបទៅ។

ធានី ៖ បើទាន់ដែរ បើមនុស្សរាប់រយនាក់ ហើយចុងភៅមានប៉ុន្មាននាក់?

វ៉ន : ចុងក្រោយគេច្រើនដែរ គេឲ្យប្រធានកងចែកគទៀតទៅ ដូចថាម៉ាកង១០០នាក់ចឹង គេឲ្យ២កញ្ចេរទៅ ។

ធានី : គេដាក់កញ្ចប់ៗឲ្យ?

វ៉ន : មិនមានកញ្ចប់ឲ្យ២កញ្ចេរ ចានមួយទៅ យើងទៅមានតែចាន១ស្លាបព្រាមួយ ។ របស់ដែលមានសំខាន់ជាងគេដែលយើងយកមកពន្លាំនឹង របស់ដែលយើងចាំបាច់គឺ បង្គីរ ជនីកកាប់ ស្បែកជើងអាគេបើកឲ្យយើងម៉ាសម្រាប់ ដូចថាបាត់មិនបានទេ ។ ហើយចានស្លាបព្រា របស់យើងមានប៉ុននឹងឯង របស់សំខាន់របស់យើង ។ តែបាត់ចានស្លាបព្រាមិនសូវអីទេ បើបាត់អា២នោះដឹងថាងាប់ហើយ ។

ធានី : គេសង្កេតមើលរបស់របរយើងទៀត?

វ៉ន : ហ្នឹងហើយ បើយើងមិនមានអានឹងអត់ ស្បែកជើងគេបើកឲ្យ ១០នាក់ ១០សម្រាប់ ។

ធានី : គេប្រាប់ចឹង?

វ៉ន : គេឲ្យចឹង ។

ធានី : ចុះដាច់ស្បែកជើង ដាច់អីទៅធ្វើម៉េច?

វ៉ន : ស្បែកជើងដាច់ទៅ គេមិនថាទេ តែជនីកនិងបង្គីរគឺថាកុំឲ្យបាត់ៗ ។

ធានី : ពេលដែលហូបបាយ ពេលខ្វះក្រៅពីដូចថាមានត្រីមានអីចឹង ហូបអីទៅ?

វ៉ន : មានអីហូបទៅ មានអំបិល នាងឯងប្រគល់ឲ្យអ្នកណា ថាមិនបានទេ គេដាក់ឲ្យហើយ បើមានៗក្តាមជីក បើមិនមានអត់សោះ ។

ធានី : ចឹងបើយើងអាចដើរជីកកង្កែប?

វ៉ន : អត់បានទេ ។

ធានី : ហើយចឹងធ្វើម៉េចបានហូប?

វ៉ន : អត់ទៅ អត់ពោះស្លាប់ទៅ ទៅជីកទៅវៃចោល គេឲ្យយើងសម្រាក តែយើងចេញពីជីកមកតាមគេ ក៏គេវៃយើងចោលដែរ ។ អត់មានអ្នកណាទៅរកទេ ដឹងទៅរកត្រង់ណាទេ បើវាលស្រែជីប្រេះក្រហែង មិនងាយទេនាង គ្មានទេនាង កុំនិយាយសួរទៅរក ទម្រាំដឹងទៅរកអីទៀត ។ ហើយមិនដឹងដើមឈើណា ស្រុកគេណា បើយើងមិនស្គាល់ស្រុកគេផង ។ ដូចនាងឯងថាគេជម្លៀសពីភ្នំពេញ ទ្រាំធ្វើចេះតែធ្វើទៅ ឆ្អែតមិនឆ្អែតត្រូវតែទ្រាំស៊ី ទ្រាំលេប ។

ធានី : ការងារធ្វើតាំងពីពេលណាដល់ពេលណា?

វ៉ន ៖ ការងារគ្មានពេលសម្រាកទេ ។

ធានី ៖ ព្រឹកឡើង ពេលព្រលឹមម៉ោងប៉ុន្មាន?

វ៉ន ៖ ពេលយប់គេដឹកទៅដាក់ទៀត យើងមកចេះ ប្រធានកងគេវាស់ទុកហើយ ។ យើងជួនណា ព្រាង១ដល់កន្លែង ជួនណាម៉ោង២ភ្ញាក់គ្នាយើងដាស់ទៅទៀតហើយ ។

ធានី ៖ ២ព្រឹក?

វ៉ន ៖ អឺ! ២យប់ ម៉ោង១០មកផ្ទះ ។

ធានី ៖ ម៉ោង១០ដដែល?

វ៉ន ៖ ម៉ោង១០យប់ ។

ធានី ៖ ចឹងសម្រាកបាន៣-៤ម៉ោង?

វ៉ន ៖ នោះនឹងហើយ ចំគ្នាមិនទាន់រួច កុមារៗគ្នាតូច អាអ្នកស្គមឈឺ កើតខ្យល់កើតអីទៅ ។

ធានី ៖ ចឹងយើងជួយគ្នាអត់?

វ៉ន ៖ ទេ! អាខ្លះក៏ជួយទៅ ស្រុកគេជួយស្រុកគេ ស្រុកយើងជួយស្រុកយើង បើស្រុកយើងមិនស្គាល់ទេក៏អត់ជួយដែរ ។

ធានី ៖ ដូចថាពេលមីងធ្វើចឹង មានអ្នកថ្មីចូលមកលាយឡំជាមួយគ្នាដែរ?

វ៉ន ៖ អត់ទេ ។

ធានី ៖ កាលពេលនឹងសុទ្ធតែអ្នកចាស់ អ្នកភូមិយើងទាំងអស់?

វ៉ន ៖ អ្នកចាស់នៅម្តុំ អ្នកថ្មីនៅម្តុំ ។

ធានី ៖ ចឹងដឹងថាអ្នកចាស់ អ្នកថ្មីគឺអត់ទាន់ទងគ្នាទេ បែកដាច់គ្នា?

វ៉ន ៖ ទេ! មិនថាបែកដាច់អីប៉ុន្មានទេ មិនទាន់ទៅដល់ ។ ដល់ពេលទៅដល់ចូលគ្នាហើយ បំបែកកម្លាំងមកផ្ទះបាត់ ។

ធានី ៖ ចឹងបានន័យថា ពេលដែលមីងធ្វើហើយ បានអ្នកថ្មីចូលមកមីងបំបែកទៅផ្ទះទៅ?

វ៉ន ៖ ទេ! មិនបំបែកទៅផ្ទះទេ បំបែកថាអាទី១ អាទី២ទៅទៀត ទៅធ្វើ ។

ធានី ៖ ចឹងធ្វើបន្តគ្នារហូត?

វ៉ន ៖ ធ្វើបន្តគ្នារហូត ។

ធានី ៖ ចឹងកាលមីងធ្វើនឹង ត្រពាំងថ្ម អត់ទាន់ធ្វើហើយទេ?

វ៉ន ៖ នេះឯង មិនទាន់លើកម្តុំផង ទៅលើកខ្លួនឯងនឹងណា ។

ធានី ៖ ដល់ពេលមីងលើកនឹង ប្រហែលជាបានកំពស់ប៉ុន្មានម៉ែត្រ មីងចាំ? មីងទៅលើកដំបូងនឹង នៅត្រពាំងថ្មនឹង?

រ៉ន ៖ ដីស្មើ ។

ធានី ៖ ចង់និយាយថា ពេលដែលមីងលើកៗហើយ ដែលមីងត្រឡប់មកកគ៣ដើម ពេលនឹងមីង លើកបានប៉ុន្មាន មើលទៅឃើញជាទំនប់ហើយឬនៅ?

រ៉ន ៖ រួចៗ ។

ធានី ៖ រួចជាទំនប់?

រ៉ន ៖ រួចជាទំនប់ នាងឯងដែលទៅត្រពាំងថ្មទេ រួចជាទំនប់បានគេឲ្យមកផ្ទះ ។

ធានី ៖ ចឹងរួចទាំងអស់គ្នា?

រ៉ន ៖ រួចទាំងអស់គ្នាបានគេឲ្យមក ។

ធានី ៖ ហើយមានគេសម្ពោធន៍មានអី?

រ៉ន ៖ សម្ពោធន៍ គេឲ្យមុខយើងទៅសម្ពោធន៍ ខ្ញុំសួរ ។

ធានី ៖ ចង់និយាយថា មីងនៅនឹង ដឹងថាអ្នកណាគេ អ្នកគ្រប់គ្រងនៅអាងត្រពាំងថ្មនឹង?

រ៉ន ៖ មិនដឹងទេ នាងអើយគ្នាច្រើនណាស់ មិនដឹងថាអ្នកណាទេ ព្រោះមិនដឹងអ្នកណាប្រធាន អ្នក ណាអី មនុស្សវាច្រើនរាប់រយ រាប់ពាន់ ។

ធានី ៖ ចង់និយាយថាអ្នកណាមេធំគេ?

រ៉ន ៖ មិនស្គាល់ទេ ។

ធានី ៖ មិនមែនអ្នកស្រុកភូមិយើង?

រ៉ន ៖ ទេ! មិនអ្នកស្រុកភូមិយើងទេ ។

ធានី ៖ ដឹងគេមកពីភូមិឃុំណា?

រ៉ន ៖ មិនដឹងគេភូមិឃុំណាទេ មិនដឹងគេទេ គេឲ្យយើងមើលណា គេស្គាល់អង្គការមួយ គេដឹកទៅ នៅក្នុងព្រៃអស់ហើយ យើងទៅស្គាល់អីៗ ថាថ្ងៃនេះអង្គការមក យើងទៅធ្វើនោះម៉េច ហៅថាខំ អង្គការគេនិយាយថាសស្រាក់សស្រាំ ។

ធានី ៖ ចុះដូចថាមីងអ្នកចាស់ចឹង ហើយមានអ្នកថ្មីមក មីងមើលទៅមានភាពខុសគ្នា រវាងអ្នកចាស់ អ្នកថ្មី?

រ៉ន ៖ ដូចតែគ្នា អ្នកថ្មី ក៏គ្នាមានខ្លួលក្បាលខ្មែរមនុស្សដូចគ្នា គ្នាខំធ្វើ គ្នាខ្លាចសាប់ដូចគ្នា ។

ធានី ៖ ចង់និយាយថា ដូចជាសិទ្ធិអី មីងអាចដើរបានអីខ្លះ?

រ៉ន ៖ អ្នកថ្មីមិនដឹងដើរត្រង់ណា អ្នកចាស់ក៏មិនដឹងដើរទៅណាទេ ។

ធានី ៖ តែគ្រាន់ពេលដែលមីងចេញពីទំនប់នឹងមក អ្នកថ្មីចូលធ្វើបន្តទៀត?

រ៉ន ៖ ទេ! គ្មានថ្មីទេ មកទាំងអស់គ្នា រួចទាំងអស់គ្នា ។ ថ្មីចាស់ អាគេរើសកម្លាំងទី១ ទី២ បើអាថ្មីមាំមួនក៏នៅជាមួយគ្នា ។

ធានី ៖ ចឹងកម្លាំងទី១ កម្លាំងមីង?

រ៉ន ៖ អឺ! កម្លាំងធំៗ កម្លាំងលើក៥ម៉ែត្ររួច ។ បើអាកម្លាំងគេថាថ្មីចាស់នោះ អត់តូចម្ល៉េះម្ល៉ក់ដែលគ្នាធ្វើមិនរួច នោះហើយគេដាក់មកទី២ នោះថ្មីគេផ្សេង ចាស់ក៏នៅជាមួយគ្នាដែរ អាចាស់ធ្វើមិនរួច ។

ធានី ៖ ចុះមីងដែលស្គាល់កងតាវ៉ាល់?

រ៉ន ៖ អត់ស្គាល់ទេ នៅផ្សេងគ្នា នៅមុខត្រពាំងថ្ម ។ កងតាវ៉ាល់នៅបុកចំកណ្តាលមុខទឹកហូរត្រពាំងថ្ម ព្រោះពេលខ្ញុំដើរទៅដល់ឃើញកូនក្មេងកាន់ក្រមា ប៉ុនមិនដឹងណាមុខតាវ៉ាល់ទេ ។ ហើយគាត់សួរថា អ្នកណាអ្នកមេ នោះហើយបើថាអគ្គការមក គេឲ្យយើងទៅដុប(ព្រៃ) ដែលដឹង មិនដឹងទេ ។

ធានី ៖ តែគ្រាន់ដឹងឬថាកងតាវ៉ាល់?

រ៉ន ៖ គ្រាន់ឮថា កងតាវ៉ាល់ ។

ធានី ៖ ហើយកងតាវ៉ាល់ កងយ៉ាងម៉េចបានគេនាំគ្នានិយាយកងនឹង?

រ៉ន ៖ កងនឹងកងពិសេសៗជាងពួកខ្ញុំទៀត ។

ធានី ៖ ពិសេសយ៉ាងម៉េច?

រ៉ន ៖ កងតាវ៉ាល់ គឺកងពិសេស បើយើងនិយាយពីទាហានសម្រាប់សមរភូមិក្តៅ ទ័ពស្រួចហើយយើងនិយាយ ។

ធានី ៖ ចឹងមីងក្រៅពីការងារនៅត្រពាំងថ្ម? មីងកងទី២ ឬកងទី១?

រ៉ន ៖ កងវាមានអាទី១កម្លាំង តែវាមានកងទី២ ក្រោយពីតាវ៉ាល់ៗទ័ពស្រួច ។

ធានី ៖ តាវ៉ាល់កងស្រួច តែកងទី១?

រ៉ន ៖ និយាយពីរៀបដូចទាហានចឹង ទាហានអាទ័ពស្រួចនឹងនៅមុខ ហើយយើងអាទ័ពទី២នៅក្រោយ ។

ធានី ៖ ចឹងតាវ៉ាល់នៅខ្ទរទឹកមុខទៅ ដល់ពេលមីងនៅបន្ទប់ទំនប់?

រ៉ន ៖ អឺ! បន្ទាប់វាយ ។

ធានី ៖ ចឹងចង់សួរមីងថា មីងអត់ស្គាល់ឈ្មោះប្រធានកងមីងទេ?

រ៉ន ៖ នោះឯងអត់មិនស្គាល់ទេ ។

ធានី ៖ ហើយប្រធានកងមីង អានឹងគេហៅកងអីគេ កង១០នាក់ ២០នាក់?

រ៉ន ៖ អាក្រុម១០នាក់ ២០នាក់ អា១០០មិនដឹងអាណាមេអ្នកណាកង ។

ធានី ៖ តែដឹងទេ នៅក្នុងក្រុមមីងមានឈ្មោះអីគេ?

រ៉ន ៖ ក្រុមអ្នកភូមិគ្នាឯង២-៣នាក់ ប៉ុន្មាននាក់ដែលប្រាប់មិញណា ដែល ។

ធានី ៖ ដែលឈ្មោះអីគេដែលប្រធាន?

រ៉ន ៖ ទេ! គ្មានអ្នកណាប្រធានទេ បើប្រធានកុំហៅអញធ្វើប្រធានអញស្អប់ណាស់ ដឹងរូប ទេ! អញស្អប់ណាស់ អញមិនបាច់ធ្វើទេ មិនបាច់ប្រើទេ ចឹងបើគេប្រាប់មកពីនោះថាយ៉ាងម៉េច ប្រាប់ទាំងអស់គ្នាទៅ យើងចាស់ហើយប្រយ័ត្នគេវ៉ៃក្បាលងាប់ ។

ធានី ៖ ចឹងនៅក្នុងកងមីងមានគ្នាប៉ុន្មាននាក់?

រ៉ន ៖ ១០នាក់ គ្មានអ្នកណាប្រធានទេ ។

ធានី ៖ ស្តាប់ពីណាគេ?

រ៉ន ៖ ទេ! គេស្រែកហើយ ថ្ងៃនេះទៅលើកនោះ ។

ធានី ៖ អ្នកណាស្រែក?

រ៉ន ៖ ប្រធានគេ មានអ្នកស្រែបន្តគ្នា ។

ធានី ៖ ចុះបើគេចេះតែស្រែកៗ?

រ៉ន ៖ ស្រុកផ្សេងគ្នា វាមានមនុស្ស ប៉ុនវាអត់មានស្គាល់គ្នា ។

ធានី ៖ គ្រាន់ហើយអត់ស្គាល់ឈ្មោះគាត់ ឃើញមុខគាត់តែអត់ស្គាល់ ឬយ៉ាងម៉េច?

រ៉ន ៖ អត់ស្គាល់ឈ្មោហ ហើយវាភ្លេចអស់ទៅហើយ ។

ធានី ៖ ពេលធ្វើហើយត្រពាំងថ្មហើយ ទៅនៅគ៣ដើម?

រ៉ន ៖ នៅគ៣ដើម ។

ធានី ៖ ធ្វើអីគេ?

រ៉ន ៖ ធ្វើស្រែប្រាំង ស្រូវវស្សា ។

ធានី ៖ ធ្វើស្រែប្រាំង ឬស្រែវស្សា?

រ៉ន ៖ ធ្វើទាំងពីមុខ ។

ធានី ៖ កាលពេលទៅដំបូង ធ្វើប្រាំងហើយបានធ្វើវស្សា ឬក៏ធ្វើវស្សាហើយធ្វើប្រាំង?

រ៉ន ៖ ធ្វើវស្សាហើយ ធ្វើប្រាំង ។

ធានី ៖ នៅរហូតដល់ពេលណាទៅ?

រ៉ន ៖ វៀតណាមមក ។

ធានី ៖ បានមីងត្រឡប់មកផ្ទះ?

រ៉ន ៖ ហ្នឹងហើយបានមកផ្ទះ នឹងបែកមិនដឹងអ្នកណាទៅខាងណា នាងឯងសន្មតដូចថានាងឯងមាន រ៉ាឡូមួយ នាងឯងទៅប៉ុននោះឯង អត់មានអ្នកណាយកអីទេ រត់ឲ្យរស់បាន ។

ធានី ៖ មកស្រុកយើង មកភូមិយើង?

រ៉ន ៖ មិនទាន់មកភូមិទេ មកចាំវៀតណាមមកនៅថ្នល់ អត់ហ៊ានមកទេ ។

ធានី ៖ ម៉េចចឹង?

រ៉ន ៖ ចុះបើខ្មែរក្រហមនៅនេះមិនទាន់ចេញទៅ យើងត្រូវដើរតាមចាំទាហាន មកទាហានតាមផ្លូវនោះ ខ្ញុំនៅខាងជើងនោះ មកឈរ នៅព្រៃមាន់ ។ ដល់ពុថាមកចូលមកហើយ បានយើងចូលដែល ។ ប៉ុននោះហើយ លុះយប់ឡើងគេរត់មកគៀរយើងម្ដងៗទៀត ។

ធានី ៖ មានចឹងទៀត?

រ៉ន ៖ មាន ដែលគេប្រមូលមកទៀត ។

ធានី ៖ តែមីងរត់ទៅដែរអត់?

រ៉ន ៖ អត់ ឲ្យតែរួចអាងតែនេះ ។

ធានី ៖ ម៉េចបានមីងអត់ទៅ?

រ៉ន ៖ អើយ! ចង់ទៅរកអីទៀត លោកអើយលោក ។

ធានី ៖ ចឹងចង់សួរមីងថា អាធ្វើការងាររស់នឹងលំបាក ការងាមីងនិយាយថាលើកទំនប់នៅសាលាក្រហមផង លើកទំនប់នៅត្រពាំងថ្មផង ធ្វើស្រែធ្វើចំការអី លើកភ្លឺស្រែតិចតួច តើមីងគិតថាការងាររស់នឹង មួយណាពិបាកជាងគេ?

រ៉ន ៖ អួយ! ពិបាកទាំងអស់នឹង គេមិនឲ្យបាយស៊ីនឹង ពិបាកជាងគេ ពិបាកលើទំនប់ត្រពាំងថ្មនេះវាខ្លាំងជាងគេ វាមិនមានទឹកផឹក ។

ធានី ៖ អត់មានទឹកផឹកគ្រប់គ្រាន់?

រ៉ន ៖ ហ្នឹងហើយ ។

ធានី ៖ ចុះទឹកផឹកអត់ចឹង ធ្វើម៉េចមានទឹកអី?

រ៉ន : អើយ! មិនបាច់មុជទេ ៦-៧ថ្ងៃអត់មានមុជទេ អាកើតថ្ងៃដូចមិនកើត ។

ធានី : ហើយយើងស្រីៗចឹង យើងធ្វើម៉េចទៅ?

រ៉ន : ស្ងួ អត់មានទឹកទេ ។

ធានី : ក្រែងលើកទំនប់ចឹង វាត្រូវមានខាងណាមានទឹកខាងណាអត់ទឹក?

រ៉ន : អត់មានទឹកទេ ។

ធានី : ចឹងបានទឹកអីហូប?

រ៉ន : ថាទៅដងទឹកស្រះ ត្រពាំងថ្ម ។

ធានី : ម្នាក់មួង បើសិនទៅរួច?

រ៉ន : ទេ! គេឲ្យទៅដងមកដឹក ។

ធានី : ប៉ុន្មានម៉ែត្រទៅ ពីត្រពាំងថ្មទៅ ថ្មពួក?

រ៉ន : ទៅកូនខ្វែងនោះដឹងប៉ុន្មានម៉ែត្រ មិនមានកាដុងដងទេ បំពង់ឫស្សី២-៣បំពង់ ដូចបំពង់...។

ធានី : ពេលណាបានមីងទៅដង ដូចថាយើងធ្វើដីកទំនប់នោះតាំងពីព្រលឹម តាំងពីព្រលប់?

រ៉ន : មានសួរហើយ ព្រឹកឡើងគេទៅវែកទៅម្នាក់អាគេអ្នកនៅនេះនៅចាំទៅ ។

ធានី : ម្នាក់មួងទៅ?

រ៉ន : អឺ! ម្នាក់មួង បើអ្នកទៅនោះដូតទៅ ដឹកទៅឲ្យផ្អែតម្នាក់ទៅ ដល់ក្រោយឡើងឲ្យនាងឯងទៅ មួង ដូតមួង ដឹកមួង ធ្វើយ៉ាងម៉េចឲ្យបាន ។

ធានី : ម្ដាយមីងឈ្មោះអី?

រ៉ន : ម្ដាយខ្ញុំឈ្មោះ ថៃ អៀម ។

ធានី : គាត់នៅរស់ទេ?

រ៉ន : ខូចអស់ហើយ ។

ធានី : គាត់ស្លាប់ដោយសារអីដែរ?

រ៉ន : គាត់ឈឺ ជម្ងឺចាស់ ។

ធានី : ឥឡូវ?

រ៉ន : សម័យនេះឯង គាត់ចាស់ៗអស់ហើយ ។

ធានី : ឪពុកមីងគាត់ឈឺឥឡូវដែរ?

រ៉ន : ចាំ!

ធានី : ចុះគ្រួសារមីងឈ្មោះអីគេ?

វ៉ន ៖ ឈ្មោះ ជឿន ។

ធានី ៖ អីគេជឿន?

វ៉ន ៖ ឈ្មោះ កែវ ជឿន ។

ធានី ៖ មីងរៀបគ្រួសារឆ្នាំប៉ុន្មាន?

វ៉ន ៖ អឺ! ដែលរាប់ទេ ដែលចាំ ។

ធានី ៖ រៀបគ្រួសារយូរនៅ ឬក៏ទើបរៀបសម័យយើង?

វ៉ន ៖ វៀតណាមចូលមកហើយ អត់បានចាប់ដៃទេ ។

ធានី ៖ បានកូនប៉ុន្មាននាក់?

វ៉ន ៖ កូន៣ ។

ធានី ៖ ហើយមីងកាលពីមុនបានរៀនបានសូត្រអីទេ?

វ៉ន ៖ មិនរៀនដល់ណាទេ តិចតួច ។

ធានី ៖ ថ្នាក់ទីប៉ុន្មាន?

វ៉ន ៖ អើយ! ទី៣ ទី៤ មិនមែនទី៣ ទី៤យើងសព្វថ្ងៃទេ យើងសព្វថ្ងៃស្រះអស្រះអាស្រះអិស្រះអី ។

ធានី ៖ កាលសម័យនឹងគេហៅទី៣ ទី៤ចឹងដែរ?

វ៉ន ៖ គេហៅបញ្ញាស ត្រូវហើយរៀនថ្នាក់ទី១០ គេហៅបញ្ញាស ។

ធានី ៖ បើយើងគិតឥឡូវ ទី៣ឥឡូវ?

វ៉ន ៖ ហ្នឹងហើយ ។

ធានី ៖ មកដល់សព្វថ្ងៃ តើមីងមានអារម្មណ៍ម៉េច?

វ៉ន ៖ មានអារម្មណ៍ម៉េច មកដល់សព្វថ្ងៃយើងរកស៊ីខ្លួនយើងៗសប្បាយចិត ។

ធានី ៖ ដល់ពេលនិយាយពីត្រពាំងថ្មចឹង មានអារម្មណ៍ម៉េចទៅ?

វ៉ន ៖ មានអារម្មណ៍ម៉េច អារម្មណ៍ដូចនាងឯងសួរខ្ញុំមុនដំបូង ខ្ញុំទឹកភ្នែក ខ្ញុំនិយាយថានិយាយមិនចេញទេ ប្រាប់មិនបានអស់សេចក្តីដែលថាទេ ព្រោះនឹកឃើញទៅដូចនៅថ្មីៗ ។

ធានី ៖ នឹកឃើញថ្មីៗ?

វ៉ន ៖ ហ្នឹងហើយ ។

ធានី ៖ អារម្មណ៍នៅមានដក់ជាប់?

វ៉ន ៖ ហ្នឹងហើយនៅដក់ដាប់ ទោះសព្វថ្ងៃនេះរស់ស្រួលណាស់ ឲ្យទៅលេងកូនក្មេង កូនមិនទៅទេ ម៉ែមិនទៅទេ ។

ធានី ៖ ម៉េចចឹងមីង?

វ៉ន ៖ រឿងមិនទៅៗមិនកើតទេ កន្លែងប្រវត្តិដូរជត់នោះ មិនទៅទេ ។

ធានី ៖ ចឹងធ្លាប់ទៅលេងនឹងស្អាត?

វ៉ន ៖ កូនថាទៅលេង សប្បាយម៉ែអើយសប្បាយ ។ វាមិនដឹងរឿងសប្បាយ ដល់យើងចាស់ៗហើយ មិនទៅទេ ។

ធានី ៖ អត់ហ៊ានទៅ?

វ៉ន ៖ អត់ទៅ វានឹកឃើញតែទៅ វាវេទនា ដល់ពេលហូបចុកក៏វេទនា អាពេកដេកក៏វេទនា ឈឺក៏វេទនា ហូបចុករាល់ថ្ងៃ បើថាទំនេរប៉ោចស្លឹកឈើស៊ីឲ្យឆ្អែតទៅ ។

ធានី ៖ នៅតែនឹកឃើញរហូត?

វ៉ន ៖ ហ្នឹងហើយនឹកឃើញ ហើយពីមុនអត់មានទឹកផង ឥឡូវគេថាទឹកឡើងស្មើច្រាំង ។

ធានី ៖ ចឹងមីងមានអីចង់បន្ថែមទៀតអត់?

វ៉ន ៖ គ្មានអីទេ នាងអើយ ។

ធានី ៖ អត់ទេ អស់ហើយ?

វ៉ន ៖ អស់ហើយ ។

ធានី ៖ ចឹងអរគុណមីងច្រើន ។

«ចប់»